ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
លេខ:...............................

# សេចក្តីណែនាំ

## ស្តីពី ការស្នើសុំផ្តល់លិខិតឆ្លងដែនសារជាថ្មីរបស់ប្រជាពលរដ្ឋ

ដើម្បីសម្រួលដល់ប្រជាពលរដ្ឋក្នុងការស្នើសុំផ្តល់លិខិតឆ្លងដែនសារជាថ្មី នៅតាមបណ្តាសាខា និងទីស្នាក់ការ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សូមធ្វើការណែនាំអំពីនីតិវិធី និងលក្ខខណ្ឌដូចខាងក្រោម ៖

- ករណីលិខិតឆ្លងដែនខូច រហែក ឬ ផុតសុពលភាព ត្រូវ៖
  + តម្រូវឱ្យភ្ជាប់មកជាមួយនូវលិខិតឆ្លងដែនខូច រហែក ឬផុតសុពលភាព
  + ធ្វើសំណើស្នើសុំផ្តល់លិខិតឆ្លងដែនសារជាថ្មី
  + បំពេញនីតិវិធី និងលក្ខខណ្ឌដូចការស្នើសុំលិខិតឆ្លងដែនលើកទី១
- ករណីលិខិតឆ្លងដែនបាត់ ត្រូវ ៖
  + តម្រូវឱ្យមានពាក្យបណ្តឹងស្តីពីការបាត់ ដែលទទួលស្គាល់ដោយអាជ្ញាធរ មានសមត្ថកិច្ច
  + ធ្វើសំណើស្នើសុំផ្តល់លិខិតឆ្លងដែនសារជាថ្មី
  + បំពេញនីតិវិធី និងលក្ខខណ្ឌដូចការស្នើសុំលិខិតឆ្លងដែនលើកទី១
- ប្រសិនបើ ការស្នើសុំលិខិតឆ្លងដែនថ្មី មានទិន្នន័យខុសពីលិខិតឆ្លងដែនមុន ត្រូវមកដាក់ពាក្យស្នើសុំ និងបំពេញនីតិវិធីនៅនាយកដ្ឋានលិខិតឆ្លងដែនដោយផ្ទាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៧កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២០